ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១០២៥០/២៥៧ កសក.អល

ថ្ងៃ សុក្រ ១១ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២៤

## ជម្រាបមក

## លោកប្រធានក្រុមហ៊ុន ខេ ខេ អេស ១៥៣ ៦.ក

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការថែទាំ ជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស ប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការថែទាំ ជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេសប្រចាំឆ្នាំ២០២៤ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម លោកប្រធាន ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន របស់លោកដើម្បីធ្វើការថែទាំ ជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស ប្រចាំឆ្នាំ២០២៤ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន ៤២៥ ៩៨៣ ៤០០៖០០ (បួនរយម្ភៃប្រាំលានប្រាំបួនរយប៉ែតសិបបីពាន់បួនរយរៀលគត់) ជាតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាបជាព័ត៌មានតាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានពីខ្ញុំ ។

ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អនុប្រធានទី១

គឹម សុន

**ចម្លងជូន៖**
- នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
- ក្រុមហ៊ុន ឡុង ហាប់ អ៊ីមផត អិចផត
- ក្រុមហ៊ុន ភី អេស ឌី អិន ខមមើស
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៣ ០០៨ អ៊ីមែល: info@maff.gov.kh